ការសាកល្បងសមត្ថភាព ផ្នែកទី៤ បឋមសិក្សាថ្នាក់ទី៦ គណិតវិទ្យា១【៦】 (១)

ប្រាំមួយ មួយ
ចូលជ្រើសរើសវត្ថុដែលមានទម្ងន់ប្រហែល១គីឡូក្រាម ក្នុងចំណោមលេខ១ ដល់លេខ៤ ខាងក្រោម
បន្ទាប់មកសរសេរលេខនោះ។
ទម្ងន់សុទ្ធរបស់កាតាសិស្សបឋមចំនួន១
ទម្ងន់របស់កាក់១យ៉េនចំនួន១
ទម្ងន់របស់ប្រអប់លោតរំលងចំនួន៥ជាន់
ទម្ងន់របស់កូនកន្សែងដៃ១
តើទម្ងន់១គីឡូក្រាមប្រហែលធ្ងន់ប៉ុណ្ណាទៅណ?
និយាយអញ្ចឹងនៅម៉ោងគណិតវិទ្យា យើងបានរៀនទាក់ទងនឹងចំណុះ និងទម្ងន់របស់ទឹកហើយមិនអញ្ចឹង។
ទឹក១លីត្រ ស្មើ ១គីឡូក្រាមមិនថាចឹង។
នៅជុំវិញខ្លួនយើង តើមានវត្ថុអ្វីដែលមានទម្ងន់១គីឡូក្រាមទៅណ?
អូ! គឺទឹកដោះគោមួយប្រអប់។
យើងធ្វើការប្រៀបធៀបទៅនឹងទឹកដោះគោមួយប្រអប់ទៅ ប្រហែលជាអាចទៅកើត។
តោះយើងសាកប្រធៀបពីរបស់ដែលតូចទៅ។
កាក់១យ៉េនមានទម្ងន់ស្រាលណាស់។
តាមពិតទៅ កាក់១យ៉េនមានទម្ងន់ប្រហែល១ក្រាមតែប៉ុណ្ណោះ។
១ក្រាម និង ១គីឡូក្រាម ខុសគ្នាមិនអញ្ចឹង។
បន្ទាប់មក កន្សែងដៃ មានអារម្មណ៍ថាធ្ងន់ជាងកាក់១យ៉េន។
តែបើប្រៀបធៀបទៅនឹងទឹកដោះគោវាស្រាលខ្លាំងណាស់។
បន្ទាប់មកគឺកាតាប។
មានអារម្មណ៍ថាមានទម្ងន់ប្រហែលគ្នា។
ហ្នឹងហើយ មានទម្ងន់ប្រហែលគ្នា។
ប៉ុន្តែប្រៀបធៀបជាមួយប្រអប់លោតរំលងសាកមើលសិន។
អួយ! ធ្ងន់។ លើកតែម្នាក់ឯងទៅមិនរួចទេ។
សរុបទៅ ចម្លើយគឺលេខ១។
ការដែលយើងធ្វើការសម្គាល់ពីទម្ងន់របស់វត្ថុ ក្នុងជីវភាពប្រចាំថ្ងៃជាការសំខាន់មិនអញ្ចឹង។
តោះ ចាប់ពីពេលនេះទៅសាកស្វែងរកវត្ថុដែលមានទម្ងន់១គីឡូក្រាមដែលមាននៅក្នុងផ្ទះទាំងអស់គ្នា។
តោះសាកធ្វើទាំងអស់គ្នា។